# យើងរៀនអាន

## ថ្នាក់ទី ‹‹១››

CA 7

Lok Mea NUON KAN
弟の時代の1年生
1962

ដើម្បីបំពេញសេចក្ដីត្រូវការ នៃសាលាបឋមសិក្សា យើងខាងផ្នែកមេអានសម្រាប់កុមារអាយុ ៦ និង ៧ ឆ្នាំ អោយបានស្របទៅតាមចលនានៃចិត្តសាស្ត្រសព្វថ្ងៃមួយយ៉ាង ហើយនិងដើម្បីបានជាសម្ភារៈខ្លះជួយផ្ដល់ដល់ការកែទំរង់សិក្សាអោយបានស្របទៅតាមគំនិតកម្មវិធីថ្មី មួយយ៉ាងទៀត គណៈកម្មការជាតិពិនិត្យសៀវភៅ បានរៀបចំតែងសៀវភៅ យើងរៀនអាននេះឡើង ។

សៀវភៅនេះចែកជាឈុត ដូចតទៅ ៖

ឈុតទី ១

- អំពីរបៀបសរសេរ
- ស្រះ និង ព្យញ្ជនៈ

យើងបានសង្កេតឃើញថា សិស្សសាលាសព្វថ្ងៃសរសេរអក្សរអាក្រក់សឹងគ្រប់គ្នា ដោយហេតុនេះ ចាប់តាំងពីទំព័រជាខាងដើមនៃសៀវភៅយើងរៀនអាន នេះ យើងបានចាត់ជារបៀបអោយនូវសិស្ស ហាត់គូសបន្ទាត់ទ្រេតជាមុន មុននឹងរៀនសរសេរព្យញ្ជនៈ និង ស្រះ ។ អក្សរធំតូចទាំងឡាយក្នុងយើងរៀនអាន សុទ្ធសឹងសរសេរដោយដៃទាំងអស់ ។ ទាំងនេះព្រោះយើងចង់រៀបចំតួអក្សរអោយអានខ្លាតត្រឹមត្រូវអោយសិស្សចេះសរសេរ តួ ជើង សក់ ដាក់តាមកន្លែង អោយមានប្រវែងទំហំសមគ្នាទៅវិញទៅមកកុំអោយមើលទៅឃើញច្រងេងច្រងាងពេក នាំអោយសល់វល់ដល់ក្មេងក្នុងការរៀនអាន និង ហាត់គ្រាប់សរសេរ ។

យើងយល់ថា លោកគ្រូ អ្នកគ្រូ មានការចាប់អារម្មណ៍ខ្លះលើមេរៀន យើងរៀនអានជាមិនខាន ព្រោះចាប់តាំងពីទំព័រទី៤ទៅ យើងចាប់បង្រៀនព្យញ្ជនៈ និងស្រៈជាប់ជាមួយគ្នា យើងមិនដាក់អោយសិស្សរៀន ហូរហែដូចដូចសៀវភៅមុនដែលជាស្នាដៃនៃអ្នកនិពន្ធរៀមច្បងយើងទេ ។ ដទៃពីនេះ យើងបានជ្រើសរើសព្យញ្ជនៈ និង ស្រៈ ដែលយើងយល់ថា សិស្សងាយសរសេរ ងាយអាន ងាយយល់ ងាយចាំមកតំរៀបដាក់ជូនលោកគ្រូបង្រៀនតាមលំដាប់ថ្នាក់មុនក្រោយ ។ ការរៀបចំបែបនេះ មិនមែនបានសេចក្តីថា យើងបង្ខំអោយលោកគ្រូធ្វើតាមយើងទាំងអស់នោះក៏ទេដែរ ក្នុងករណីនេះ យើងទុកសេរីភាពជូនលោកគ្រូ អ្នកគ្រូលៃលកកែសំរួល បង្រៀនសិស្សតាមអធ្យាស្រ័យ និង ការពិសោធន៍អស់លោកផងទៀតចុះ ។

ប្រការមួយទៀត ព្យញ្ជនៈខ្លះដូចជា ឋ ឱ ឡ ដ្ឋ ស្រៈខ្លះដូចជា ឿ ៀ ដែលមានសម្លេងតែមួយ ស្រះពេញតួដូចជា ឧ ឪ ឫ ឬ ឥ ឦ ឭ ឮ ឯ ឰ យើងទុកបង្រៀនជាខាងក្រោយ ក្នុងពេលដែលសិស្សចេះព្យញ្ជនៈ ឃោសៈខ្លះ អឃោសៈ ចប់ស្រេចបាច់ហើយ ។ទាំងនេះព្រោះយើងចង់បង្អាត់នូវការពិបាកខ្លះដែលគួររាប់បានជាឧបសគ្គក្នុងការរៀនអាននៃក្មេងតូចៗនេះដែរ ។

ឈុតទី ២

- អំពីពាក្យ និង ឃ្លា
- ពាក្យណាដែលប្រកបទៅបានពីរបែប ដូចជា ទូកង ទូក-ង ផ្លែញ ផ្លែ-ញ ខ្សែក ខ្សែ-ក ទេសឯកស ទេស-ឯក-ស ... ។
- ពាក្យណាដែលនាំឲ្យសិស្សអានទៅហើយ នឹកឃើញរូបារម្មន៍អាក្រក់ផល់ វត្ថុគួរខ្ពើម គួរខ្លាច ដូចជា ដំបៅ តំរង់ ខ្មោច ... ។
- ពាក្យសម្តីណាដែលផ្ទុយ និង ការពិត ដូចជា ឥសី យក្ស ... ។
- ឃ្លាដែលមិនសមហេតុមិនសមផល

យើងបានចៀសវាងមិនយកមកប្រើក្នុង (យើងរៀនអាន) ទាំងអស់ ។

ជាឃ្លាខ្លី ៗ មានន័យស្របទៅតាមរឹក និង ភាពរស់នៅពិត ៗ របស់វា ។
ឯពាក្យទាំងអស់ក្នុង យើងរៀនអាន នេះមានជាង ៦០០ ។ ចំនួននេះ
យើងឃើញថាច្រើនបន្តិចទៅហើយ តែយើងមិនអាចបំព្រួញជាលើកដំបូង
អោយតិចជាងនេះបានឡើយ ។

ឈុតទី ៣

- អំពីអត្ថបទ

យើងបានតែងអត្ថបទជារឿងខ្លី ៗ ប្រកបដោយពាក្យ និង ឃ្លាងាយ ៗ
មិនអោយលើសសមត្ថភាពក្មេងដែលនៅក្នុងវ័យត្រូវការចលនា ត្រូវការ
លេង ត្រូវការឆ្ងល់ ត្រូវការចង់ចេះ ចង់ដឹង ចង់សប្បាយ ... ។

ក្នុងឃ្លានិមួយ ៗ យើងមិនសូវគិតតម្រូវតាមក្បួនវេយ្យាករណ៍ប៉ុន្មានទេ
យើងជាប់ចិត្តគំនិតតែនឹងរៀបពាក្យអោយទៅជាភាសាក្មេង ដើម្បីឲ្យក្មេង
យល់គំនិតអត្ថបទ ប្រយោជន៍បំផុសមនោគតិ បំផុសការសង្កេតបណ្ដុះវិញ្ញាណ
ហើយ និង បណ្ដុះ សញ្ញាណវិទ្យាសាស្ត្រ ។

ឈុតទី ៤

- អំពីរូបភាព

យើងរៀនអាន សម្បូរដោយរូបភាព ដែលយើងបានរំលេចនៅគ្រប់ទំព័រ
តាមសោភ័ណវិជ្ជា ។ យើងយល់ថា បើលោកគ្រូជួយបណ្ដុះសិស្សអោយស្គាល់
នូវគំនិត និង អាការដែលរូបបានសម្ដែងនោះ នឹងនាំឲ្យសិស្សចេះមើលគំនូរ
ឆាប់យល់អត្ថបទ ហើយថែមទាំងនាំឲ្យទាក់ចិត្តសិស្សក្នុងការអានទៀតផង ។

សរុបសេចក្ដីទៅ សៀវភៅនេះធ្វើឡើងដោយមានបំណងអោយក្មេងឆាប់
ចេះអាន អោយក្មេងដក់ចិត្តក្នុងការអាន អោយមានការអានក្នុងសន្ដានចិត្ត
វាទៅថ្ងៃក្រោយទៀត ។

ឥឡូវនេះយើងសូមជូនសៀវភៅ <<**យើងរៀនអាន**>> ដល់លោកគ្រូ អ្នកគ្រូ ហើយយើងរីករាយនឹងរង់ចាំទទួលនូវយោបល់ទាំងឡាយ ដែលលោកគ្រូ អ្នកគ្រូ នឹងផ្តល់មកអោយយើងខ្ញុំ ប្រយោជន៍នឹងបានកែសំរួល << យើងរៀនអាន់ >> នេះអោយបានកាន់តែប្រពៃឡើង ។

គណៈកម្មការជាតិពិនិត្យសៀវភៅផ្នែកទី ២

ប្រធាន : ឈូក - ម៉ឹង - មៅ

សមាជិក

| | |
|---|---|
| ប៉ាន់ - ឡូវ | តាន់ - អ៊ុំម |
| ផៃ - ផេង | ហួត - សី |
| គង់ - ធូ | ម៉ៃ - លន់ |
| ងួន - យ៉ុម | ទីវ - នុយ |
| ទី - សែម | ហួរ - ហេង |
| តិក - ធូក | ប៉ក់សាម័យ - ម័ង់សាណា |

# <u>អារម្ភកថា</u>

## កែសម្រួលលើកទី ១ ឆ្នាំ ១៩៦៩

សៀវភៅយើងរៀនអានថ្នាក់ទី ១២ នេះបានរៀបរៀង នៅឆ្នាំ ១៩៥៩ ហើយបោះពុម្ពលើកដំបូងក្នុងឆ្នាំ ១៩៦០ <<យើងរៀនអាន>>បានបោះពុម្ព ៣១ លើកហើយ .

យើងរៀនអានថ្នាក់ទី ១២ ត្រូវបានកែសម្រួលលើកទី១ នៅឆ្នាំ ១៩៦៩ ។ ការកែប្រែនេះ ធ្វើឡើងទៅតាមការវិវត្តទូទៅនៃសៀវភៅសិក្សាផង សម្រួលទៅតាមយោបល់ និង ពិសោធន៍របស់អ្នកប្រើ ដែលបានផ្តល់យោបល់ល្អ ៗ ទៅទីចាត់ការគរុកោសល្យផង ។

ទីចាត់ការគរុកោសល្យ

ដីការបង្គាប់លេខ ៣៣ គ-ក ៩-៦៩

គួរតែមានសៀវភៅ

((យើងរៀនអាន))

មួយក្បាលទុកនៅផ្ទះ

ទុកដើម្បីជួយបង្រៀន

ថែមឲ្យកូនចៅរបស់

លោកអ្នកចេះអាននិង

សសេរអក្សរជាតិ ...



# សង្ហា



# នារី



ไ

ก ไ ก

ก ก ก

ก ๆ





# ຳ

# ກ ຳ ກຳ



# ກຳ ກຳ ກຳ

(សារឡើងវិញ)



ក ក ក

កា កា កា

កាំ កាំ កាំ





ด

ด

ด า ดา

ดา ดา ดา

ា ប

ត តុ

ា ា

តុ តុ តុ

ា ា ា



ត តុ

ប ប

តុ តុ តុ

ប ប ប



ក ត



ាំ កាំ តាំ

ា តា កា

ុ កុ តុ

ូ តូ កូ

ເ ເ້ ເ໊

ເ ເກ ເຕ

ເ້ ເຕ້ ເກ້

ເ໊ ເກ໊ ເຕ໊





เา เ่า เาะ



เา เดา เกา

เ่า เก่า เด่า



เาะ เดาะ เกาะ



# េ ើ ឿ ោ ៅ ាំ ោះ

# កេ កើ កោ កៅ

# កឿ កាំ កោះ

# កៅចៃ បូណោ កកេរ



◌ុះ េ◌ះ

ចុ



ច ◌ុះ ចុះ

ចុះ ចុះ ចុះ

ច េ◌ះ ចេះ

ចេះ ចេះ ចេះ

នារីចាំតាចុះ

ິ ີ ຶ ື

ດ ິ ດິ

ກ ີ ກີ

ບ ຶ ບຶ

ກ ື ກື

ດິ ບີ ກຶ ດື



เ ี ํ ํ

่

ดิ เ ี เดี

บิ ํ บิํ

กิ ํ กิํ

ดาเดา บำบิํการ



ុះ េះ ំ ុំ ិ ី ឹ ឺ ើ

ចុះ កេះ តិ ចី កឹ តឺ ចើ តំ កុំ



ចៅកេ ចេះដើរតេះតះ

ភ្ភ

ភ ា ភ

ភ ភ ភ

ភ ្ភ ភ្ភ

ភ្ភ ភ្ភ ភ្ភ





ៃ ោ ោះ

គ ៃ គៃ

គ ោ គោ

គ ោះ គោះ

គៃ គោ គោះ



គោៗ

េ ើ ុំ

ភ

ភ ើ ភើ

ភ េ ភេ

ភ ុំ ភុំ

ភើ ភេ ភុំ



ម្ម

ម ូ មូ

ម ាំ មាំ

ម ី មី

ម ើ មើ

មមី មមើ



នារីញាំមី

(សារឡើងវិញ)

# គ ភ ម

គ គា គិ គី គឹ គឺ

ភុ ភូ ភួ មើ មេ មៃ មែ

គោ គៅ ភុំ ភំ ភាំ ភះ

មុះ មេះ មោះ

បូពភ មមើ

មានារីគូរភៅ



ញ ្ញ

ពិ ពី ពឹ ពឺ

ញិ ញី ញឹ ញឺ

ពពែញីពីរ



# ឃ្យ ល្វ ឿ

រៀ លៀ ទៀ ឃៀ

រឿ ទឿ ឃឿ លឿ

ឃំ ឃូ លុះ



ពូលើកអាឃូ



# ពញយឈ

ពាពិពីពឹពឺ ញុញូញួ យើ

យឿយៀ ឈេឈែឈៃឈោ

ឈៅ រុំរឹរាំ រះ ។ យិះ រេះ ពោះ

បូណា ! ពពែញី ពូយី ទេតើ!



# ហ្វឹកហាត់

ចចាចិចីចឹចឺ ហុហូហួ សើ

សឿសៀសេសែសៃ ហោហៅ

សុំសំសាំសះ សុះ សេះ សោះ ។

ពូថៅ៥ បូណាគូរសេះ



ណារីសរសេរ ។



# ខ ឃ ឆ ឈ
្ខ ្ឃ ្ឆ ្ឈ

ខៃឃៃ ខោឃោ ខាំឃាំ ខះឃះ

ឆាឈា ឆេឈេ ឆេះឈេះ

ឆុំឈុំ ឆៅឈៅ ខោខ្ញុំឆេះ

ខូរគោ ឈឺដៃ ចៅឈុំចេះសំពះ

នារីឈឺពោះ ។



(សារឡើងវិញ)

# ផសហខយឆឈ

ឈឈាឈិ ឆីឆឹឆឺ យុយូយួ

ខើខឿខៀ ហេហែហៃ សោសៅ

សុំ ចំចាំចះ ។ ឆុះ ឈោះ ខះ

កុំឆាឆៅគេ ឈើឆេះ មីឆា

ខែមេសា

ពូឆាំពុះឈើ ។



# ឃ្ង ឃ៉្ក ឃ៉្ព ប្រ

ធធាធោធៅធាំ ឌិឌីឌឹឌឺ ដេដែដៃ

រឿរៀរើុំ ដំដាំដុះ រះរោះ ផេះផៃ

ធូធុំធំ ដីដូដើដុំ រីរោរំ ។

នារីសំដីពីរោះ ។ ខែរះ ។



សុភីដើរសំដៅចំការអំពៅ

បញា បញោ ពៅប៉ែបោះ ជីជូជឿ

ផេជូផោជុំ ផះផោះ ឯងាឡឿងំ

ណាណេណឹណូ ណេណើ៍ណែ ដំណាំ ដំងឺ

ចំណើជូវ ងីងើ បំពៅ ។ មេអំពៅ

ឲហើរទោលើផ្កា





អាជុំរាំរបាំខ្មែរ

# ទ ឡ ន



ឡឡា ឡោះ ឡាំ ឡៅ

ទទាទិទីទឹទឺ នុនូនួនុំ

នាំ នះ ទោះ នោះ ឡោះ

នៀនឿ ទេទើទៃ

ទៅណា ជំនឿ ឡូឡា



ទីនោះ ទំពាន់ នាឡិកាដៃ

ចៅជាញុាំសំឡកកូរទា

ទៅណា នាឡិកា រទេះគោ

ចំការអំពៅ រងា ជឿសំដី



យួរទា មេឃុំ លីឈើ ពូកែ

ពោះ ពពែ សុភា សំណាចីធុំ

ហូរហែ ខ្សឿះខ្សោះ ។

តាសំបេះដាំដំណាំ ។ ម៉ែខ្ញុំ

ដាំបបរ ។ នារីទៅសាលា

ប៉ាខ្ញុំបេះផ្កាចំប៉ា ។





# ង៉ញ៉ប៉ម៉យ៉រ៉វ៉

ង៉ា នុិ ញី ញុឹ ញ៉ុ ញ៉ូ មុី ម៉េ ម៉ែ

យ៉ៃ យ៉ោ យ៉ៅ រុាំ រ៉ះ រុះ រ៉េះ រ៉ោះ

ប៉ា បុី បុើ ប៉េ ប៉ូ ប៉ោ ប៉ៅ ។

ចាបុី បារុី រយ៉ា ម៉េះ ម៉ោះ។

តាវ៉ៅយ៉ំ។ដំណើរអាវ៉ាញុាំញុើ។



សំដីប៉ែឡាំ។កុមារីនេះញ៉ោះញ៉ោះ។

បារីនៅបោកប៉ៅខោប៉ា ។

សារុំទះស្គរយីកេ ។ ។

# អ៊ ប៊ ហ៊ ស៊



ប៊ុ ប៊ិ ប៊ី ប៊ឹ ប៊ឺ ស៊ុ ស៊ូ ស៊ើ

ហ៊េ ហ៊ែ ហ៊ៃ ហ៊ោ ស៊ុំ ស៊ាំ

ហ៊ំ ប៊ុះ ប៊េះ ប៊ោះ ។

តៅហ៊ូ ទំហូ កៅស៊ូ

ភាស៊ី តស៊ូ សាប៊ូ៧ដុំ។

សុណាស៊ីនំគួរ។ចៅស៊ុទះដៃហ៊ោ ។

តាប៊ូផាហោរា ។ នារីយំហ៊ុ ៗ



# កន កន់ កាន កាន់
# គន គន់ គាន គាន់

ចាន ចាន់ បាន បាន់ ងាន ងាន់ មាន មាន់
ប៉ាន រាន រាន់ កិន ចិន មិន រិន កុន ងុន
មុន គុន គុណ ដូន សូន សូន្យ លូន ពូន ពួន
បួន កើន រៀន កៀន ពេន បែន មែន ពោន។
ដីដូន ទាបាន ចំនួន មិនមែន ។
ខ្ញុំបានទៅរៀន ។ អាចាន់មានមេមាន់បួន ។
រទេះឡាននេះបរលឿន ។ អាសេនពួននៅកៀន។
ចៅមានបេះផ្កាឯស្ពួន ។
ចៅសនប៉ានជិះសេះឈើ។







# កយ កាយ គយ គាយ

បាយ ចាយ ងាយ ជាយ

ប៉ុយ ផុយ រុយ លុយ

ផួយ ជួយ មួយ រលួយ

កើយ រហើយ ងើយ នឿយ

រឿយ កោយ រោយ ។

ទីទុយហើរ ។ ខ្ញុំមានមេមាន់មួយ។
ចៅសយញ៉ាំបាយ ។ នារីខំរៀន
និយាយ ។ សុខាចេះសរសេរហើយ ។



# កម កាម គម គាម
# កាវ គាវ

តាម ញ៉ាម នាម បៀម ញ៉ឹម ទឹម ភូមិ បូម ហើម

ផើម ចោម នោម គោម ។

ខាវ បាវ អាវ កែវ ចៃវ ឡេវ ហេវ ខៀវ ទៀវ រៀវ។

តៀមកាហ្វេ ឡេមឡឹម ចំពាម ទំនៀម ឡេវអាវ រដូវ



មេមាន់ទំលើដើមមៀន ។ សារិមពូននៅ
កៀនដើមទទឹម ។ វាកាន់សាវម៉ាវញុាំ។
ឆ្មាយំម៉ាវៗ ។ ទៀវរោមខៀវ ហើរតាម
មេអំបៅ ។ មេមាន់នាំកូនដើរ ។
វាកកាយដីនៅសួន ។ មុនមាន់បានេះ
រងាយ ពូអៀមទឹមរទេះគោទៅចំការ ។
ចៅតឹមមានកែវ៨ ។



# កាច កាច់
# គាច

សាច សាច់ ឆាច ឆាច់ រាជ តិច

លិច ទិច ទុច ហុច សុច តូច ដូច

ពូជ ខូច លូច សើច វៀច លេច

បោច ទោច រោច ។

មិនបាច់ បំណាច់ ទ្រនិច កំទេច

ខោនេះដាច់ឡេវមួយ ។ ទ្រនិចនាឡិកា

នេះខូច។អាម៉ាច មិនកាចដូចអាទូចទេ។

ខ្ញុំរៀនហួចតិចៗ រួចខ្ញុំសើចញឹមៗ ។



# កង កង់ កាង កាំង

# គង គង់ គាង គាំង

ចង ចង់ ទង ទង់ តាង តាំង

ពាង ពាំង ខឹង រឹង រីង មឹង ចុង

ធុង ទូង លួង បួង មឿង ជើង

លៀង ទៀង លេង ម៉ោង ប៉ោង

ទោង កោង សាំង ទាំង រាំង ឡាំង។

កំឡាំង រនាំង ជិះទោង ននោង

ជាងទង រឹងប៉ឹង ។

ពូផេងដើរលេង ក្បែរបឹងធំ ។

ប៉ាចៅប៉េងញាំសាច់គោអាំង ។

យើងឡើងជិះទោងធាងដូង ។

គេយោងទឹកនឹងធុង ។







# កញ កញ់ កាញ កាញ់
# គញ គញ់ គាញ

**សាញ បាញ់ ទាញ ទិញ វិញ ញ៉ុញ រុញ ធុញ**

**រួញ ជួញ ឃើញ ចេញ ពេញ ដេញ ។**

**កុំសាញ សំឡាញ់ កំណាញ់ ទំនិញ គេឃើញ**

**ជំនួញ បំពេញ ចំណេញ ។**

មីងអាពាញទិញសំពត់នីឡុងទៅជួញ ។ អាពាញ
ទាញម៉ែត្រឈើមកវាស់ ។ វាឃើញទាំងអស់ដប់
ម៉ែត្រ ។ មីងវាថា សំពត់នេះរួញៗផង ។



# កប កប់ កាប កាប់
# គប គប់ គាប គាប់
# គព គភ

ចប ចប់ លេប លេប់ ជប់ ចាប ចាប់

ទាប លាភ លាប់ ផឹប ហឹប លឹប ណុប

កូប រូប រួប កួប ទើប កើប ទៀប

រៀប ទេព បែប លោភ ដោប ។

ចាប់ចាប សំណាប ដំណើប រំភើប។

សំឡាញ់ខ្ញុំទៅបាញ់ចាប។វាលបកៀន ដើមទៀប ។ វារៀបបាញ់ចាប ចាប ហើរវិងទៅចុះស៊ីសំណាប ។ សំឡាញ់ ខ្ញុំដើរទៅទាន់ ចាបកំពុងលេបគ្រាប់ ស្រូវ ។ វាទាញកៅស៊ូបាញ់ចាប ឆែប ចំពុះ ។ សំឡាញ់ខ្ញុំមានលាភ ។

កល កល់ កាល កាល់ គល គល់ គាល គាល់
កស កស់ កាស កាស់ គស គស់ គាស គាស់

កាល ផាល ជាល វាល កិល រិល
ផុល អុល ពុល ជុល ទូល ទួល កើល
មើល ដៀល ពេល ខែល ចោល គោល
បោល ។ កាស ចាស ណាស់ ជាស
វាស វាស់ រស់ ខុស មូស ជួស លួស
រើស ញើស ចៀស ចេស ទេស កែស
កោស ទោស ។



សំគាល់ អំបិល ដីវាល កំសួល រមាស
តាចាស់ មូសខាំ ឈូសឈើ
ម៉ោងប្រាំពីរ ។ ប៉ោលនាឡិកា យោលចុះ
យោលឡើង ។ អាគល់មើលគេលេងកូន
គោល។ សិស្សនេះបោសរានហាលសាលា។
អាសួសរពីស វាចុះទៅរើសលៀសឯបឹង ។





# កក កក់ កាក កាក់

# គក គក់ គាក គាក់



ម៉ាក ភាត ចឹក ទឹក រឹក រុក ទុក មុខ

ពូក ទូក មូក បើក លើក ចេក មេឃ

មែក បែក ដោក ងោក ហោក រោគ

ជំដែក ទឹកកក ។

សេករោមខៀវ ទំស៊ីចំណី លើមែក

អំពិលទឹក ។ ចំពុះវាក្រហមទុំរាងក្រងុក។

សំបកចេកទុំសំបុរលឿង ។ ពូសេកលឺ

ចបទៅកាប់ដី បានចំការចេក ។

បើផឹកទឹកឆៅមុខជានឹងកើតរោគមិនខាន។



# កត កដ បទ



កាត កាត់ ខាត ខាត់ គាត់ ឃាត់ ញាត់

ទាត់ ធាត់ ឈាត់ វាត់ សិត គិត ឃឹត ដុត

មុត ដូត កួត ពួត កើត ងៀត ដោត ។

សិតសក់ កាំបិត កាសែត សំប៉ែត

ចិតស្វាយទុំ ញាត់ពូក ជូតមុខមាត់

កុដិលោក សំពត់ហូល ។

កុំលេងកាំបិត វាមុតដៃ ។



ចៅសែតជាសិស្សពូកែលោតណាស់ ។

សុភីបានទៅមើលកុនជាមួយមិត្តវា ។

មាសំណាងជិះឡានទៅលេងប៉ោយប៉ែត

ជាមួយកូនគាត់ ។



# -ព្យញ្ជនៈ-

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម

យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អ្អ

# -លេខ-

១-២-៣-៤-៥-៦-៧-៨-៩-១០

២០-៣០-៤០-៥០-៦០-៧០-៨០-៩០

# ែ

# ក្រ ច្រ ត្រ ប្រ ស្រ
# គ្រ ជ្រ ទ្រ ព្រ ម្រ



ក្របី ក្រហម ក្រពើ គ្រួស ក្រវា ច្រាស ត្រី ត្រប់
ប្រុស ប្រាក់ ស្រះ ស្រូវ ស្រោម ស្រុកស្រែ សំបុត្រ
ស្រមោច ស្រែះខោ គ្រាប់ពោត ដើមជ្រៃ ទ្រុងជ្រូក
ខោទ្រនាប ទ្រមាក់ដំរី ព្រាប ព្រានព្រៃ ត្រីព្រួល
ព្រោះស្រូវ ប្រោមដៃ ប្រះព្រៅ ម្រេច ។

ក្របីធំមួយឈរនៅជិតគោ។ សិស្សត្រូវដុសលាងមុខមាត់រាល់ព្រឹក ។ បងស្រីបួណោកើបគ្រាប់ពោតដាក់ដាក់បាវ ។ ព្រានព្រៃពីរនាក់ទៅបាញ់ប្រើស ។
ជ្រូកនេះចូលស៊ីដំណាំតាព្រំ។
នៅកំពតមានដាំម្រេចច្រើន ។



្អ ្ង ្ន ្ម ្ប ្យ ្ញ ្វ

អ ្ក ្ឃ ្ដ ្ស ្ទ ្ហ



ក្អ ក្ង ក្ន ក្ម ក្ល ក្ប ក្យ ខ្ញ ខ្ដ ខ្ន ខ្ម ខ្ល ខ្វ

ខ្យ ខ្ស ខ្ម គ្ន គ្ម គ្ល ឃ្ន ឃ្ម ឃ្ល ឃ្វ ហ្វ

ក្អក ក្ងាន ក្នុង ក្មេង ភ្លើ ក្បែរ ខ្ញី

ខ្ញុំ ខ្ទុរ ខ្យង ខ្យល់ ខ្សែ ខ្មៅ គ្មាន ឃ្មុំ

ក្អែកហើរ ក្ដារស្រល់ ត្រីក្បក ខ្មៅដៃ

ព្រះមហាក្សត្រ ខ្លាធំ ខ្ញិតទុំ មាន់ខ្ដត ។



ក្អែកស្រែកឮខ្ញកៗ រោមវាខ្មៅស្រិល វានៅឯព្រៃជ្រៅ លើដើមឈើខ្ពស់ ។ សត្វនេះ រស់នៅជាហ្វូង។ វាប៉ិនប្រសប់ ស្រង់ក្លិនខ្មោចឆ្កែ ឆ្មា ត្រី និង សំណល់ អាហារទាំងឡាយ។ ក្អែកសាំងគ្មានខ្លាច ក្មេងទេ។ វាហើររកចំណីនៅជុំវិញរោង ជើងក្រាន និង សំបុកមាន់ ។



្ង ្ញ ្ន ្ម ្យ ្ប ្ល ្វ

អ ្ក ្ឃ ្ដ ្ឋ ្ឍ ្ហ

ច្ប ឆ្អ ឆ្ក ឆ្ង ឆ្ន ឆ្ម ឆ្ល ឆ្វ ជ ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ ត្អ ត្ន ត្ម

ត្ល ត្ប ថ្ង ថ្ន ថ្ម ថ្ល ថ្វ ទ្វ ធ្ង ធ្ន ធ្ម ធ្ល ធ្វ ធ្យ ច្បារ ឆ្អឹង ឆ្កែ

ឆ្ងាញ់ ឆ្កុក ឆ្នោត ឆ្វេង ជ្វា ឈ្ងៀម ឈ្ងុញ ឈ្លួស ឈ្លើង ត្អុក

ត្នាត ត្បាញ ថ្ងូច ថ្នេរ ថ្លាង ថ្លឹង ថ្លុក ទ្វារ ធ្មស់ ធ្មៃ ធ្លា ធ្យូង។

ច្បារដំណាំ ឆ្អឹងជំនីរ ឆ្ងាញ់ពិសា ក្តារឆ្នួន សេះឈ្មោលប្រាំ

ត្អូញត្អែរ ដើមត្នោត ធ្ងន់ធ្ងរ ថ្ងៃអាទិត្យ ថ្លៃថ្នូរ ត្បាល់ថ្ម

ធ្មេញទឹកដោះ ។

គ្រួសារខ្ញុំ ធ្វើការមិនចេះឆ្អើងឆ្អៃ ។ ថ្ងៃៗឪពុកខ្ញុំឆ្ការព្រៃ

ធ្វើច្បារ ឡើងត្នោត ។ ម៉ែខ្ញុំត្បាញសំពត់ហូល ។





–្ប –្ង –្ន –្ម –្យ ្រ– –្ស –្វ

អ –្ក –្ឃ –្ត –្ឈ –្ញ –្ហ

ប្អ ប្ដ ប្ល ផ្អ ផ្ង ផ្ញ ផ្ន ផ្ល ផ្យ ផ្ក ព្ន ព្យ ភ្ញ ភ្ន

ភ្ល ល្ង ល្ម ល្វ ស្ង ស្ញ ស្ន ស្ម ស្ល ស្អ ស្ក ស្ដ ស្ប

ប្អូន ប្ដី ប្លែក ផ្អូម ផ្ងុប ផ្ញៀរ ផ្នត់ ផ្លូវ ផ្សារ ផ្ការ ព្នៅ
ព្យួរ ភ្ញាស់ ភ្នាក់ងារ ភ្លុក ល្ង ល្មុត ល្វីង ស្ងោរ ស្នប់
ស្មា ស្ញើប ស្លៀក ស្វា ស្វាយ ស្អាត ស្ករ ស្ដារ ស្បែក ។

ប្អូនស្រី ប្ដីប្រពន្ធ ប្លោកត្រីកែក ផ្ញើសំបុត្រ ផ្នត់អាវ
ផ្លូវត្រឡែងកែង ផ្សារថ្មីធំ ផ្សិតចំបើង ម្ដាយផ្ងូតទឹកកូន
ផ្លែព្នៅទុំ ព្យួរអាវ ខ្យល់ព្យុះ ភ្លុកដំរី ត្រីស្ងោរ កើតស្អូច។

ស្វានៅក្នុងព្រៃស៊ីស្លឹកហើយនិងផ្លែឈើ ។ ជួនណាវា
ឆ្លងផ្លូវទាំងហ្វូងៗ ។ ស្វាខ្លះខ្មៅ គេហៅថាស្វាព្រាម
ខ្លះប្រផេះ គេអោយឈ្មោះថាស្វាឪ ។ ស្វាចេះធ្វើសំបុក
តែល្ងង់ ព្រោះពេលផ្គរ ព្យុះ ភ្លៀង វាមិនចេះជ្រក ។





# អ អា ឥ ឦ ឧ ឩ ឪ

# ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

ឥឡូវអ្នកនៅឯណា ? ឪពុកឯង
នៅផ្ទះឬទេ ? ទិសឦសាននៅឯនោះ ។
ម្ដេចក៏ធ្វើឫកថ្លង់ ? អ្នកឮសូរយន្តហោះ
ឬទេ ? យន្តហោះទាំង៩នេះជ្រែកពពក
ឰដ៏អាកាស ។ ឪពុកចៅឱ្យទៅដកក្រឩ
ឈូកឯបឹងធំ ។

# ពាក្យពីរព្យាង្គតំរួត

**ង្ក ង្ខ ង្គ ង្ឃ**

ចង្វា បង្កៃ ដង្ខៅ

បង្ខំ អង្គារ បង្គី

**វគ្គ : ក្ក ខ្ខ គ្គ ឃ្ឃ ង្ង**

កង្កែប សង្កាត់ អង្កាម

បង្ខិត បង្គាប់ អង្គុយ

មង្ឃុត សង្ឃឹម

**ញ្ច ញ្ឆ ញ្ជ ញ្ឈ**

កញ្ចៃ កញ្ចុះ បញ្ចុះ

បញ្ឆេះ កញ្ជើ បញ្ជើ

បញ្ឈរ

**វគ្គ : ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ**

កញ្ចាញ់ចេក ចិញ្ចើម

ចិញ្ចៀន កញ្ឆែត

ជញ្ជូន ជញ្ជាំង បញ្ឈប់



គីង្គក់លោតលើគំនរអង្កាម នៅក្បែរបង្គន់ ។ គេបោះបង្គោលឫស្សី ចងធ្វើជារបងផ្ទះ ។ ម្ដាយខ្ញុំ ទៅផ្សារទិញមង្ឃុតពីរផ្លូន ។ កញ្ជែតគេច្រើនយកមកប្រើជាអន្លក់ ។ បងស្រីខ្ញុំ ទូលស្រូវមួយកញ្ជើ ដើរលើចិញ្ចើមថ្នល់ សំដៅទៅផ្ទះ ។



ណ្ដ ណ្ឋ

កណ្ដុរ កណ្ដៀរ

បណ្ដៅ សណ្ឋាគារ

វគ្គ : ដ្ដ ឋ្ឋ ឌ ឍ ណ

កណ្ដូប កណ្ដៀតក្អម

កណ្ដៀរ បណ្ដោយ

សំណ្ដោក អណ្ដាត

ន្ត ន្ថ ន្ទ ន្ធ

កន្តំ កន្ថោរ បន្ទរ

បន្ទះ បន្ទុំ កន្ធរ

បន្ធូរ ប៉ុន្តែ

វគ្គ : ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

កន្តឹប កន្តាំង កន្ត្រង

កន្ត្រប់ បន្ថយ បន្ថែម

កន្ទក់ កន្ទុយ សន្ទូង

សន្ទូច កន្ធាយ សន្ធឹង

ម្ប ម្ផ ម្ព ម្ភ

សូម្បី កម្ពស់ សម្ភារ

វគ្គ : ប្ប ផ្ផ ព្ព ភ្ភ ម្ម

កម្ពុជា បុប្ផា ដើម្បី



បងស្រីខ្ញុំ កណ្ដៀតក្អម យកទៅដងទឹកអណ្ដូង ។ ប្អូនៗពាក់កន្ដឹប ជិះកង់ទៅទិញត្រីកន្ដ្រប់ និង ត្រីកន្ដ្រងប្រេង ។ ស្រីៗ ត្បាញកន្សែងក្រហម ដើម្បីយកទៅលក់ ។ នៅប្រទេសកម្ពុជា ការនេសាទត្រីជារបរមួយយ៉ាងសំខាន់ សំរាប់សេដ្ឋកិច្ចជាតិ ។

# ព្យាង្គតំរួត (សេសវគ្គ)

ពន្យារ ពន្យល់ ជង្រុក បង្រួញ បន្លំ ពន្លា

គន្លង គន្លាក់អាចម៍ កន្លាត កន្លែង បង្វិល

សង្វាត ទន្សាយ ទន្សោង សន្សើម បង្ហាត់

បង្អួច ចង្អុល ។

លោកគ្រូបាននាំសិស្ស ចេញទៅបង្រៀន

រង្វាស់រង្វាល់ ក្រៅសាលា ។



កណ្ដុរជាសត្វចង្រៃណាស់ វាច្រើននៅក្នុងជង្រុកស្រូវយើង ។ សាមិត្តអង្គុយមើលសត្វចាប ទំលើមែកអំពិលទឹក ។ បងប្រុសបូណា ធ្វើគ្រូបង្ហាត់នៅខេត្តសៀមរាប។ ទន្សាយផឹកតែទឹកសន្សើមទេ ព្រោះវាភ្លាល់ចាញ់ខ្យង ។

## សំរាប់គ្រូ

ក្បួនវិធីបញ្ចាក់សំឡេង នៃ ព្យញ្ជនៈ សំយោគ

វិធាន - សម្លេងនៃព្យញ្ជនៈ គឺជាសម្លេងរបស់ជើងជាដរាប លើកលែងតែពួក ((អ៊)) ចុងវគ្គនិងសេសវគ្គ។

១- ពួកព្យញ្ជនៈ សំយោគដែលយកសម្លេងរបស់ជើងតំរួត

ឧ ៖ ខ្ជ ខ្ឈ ខ្ព ឆ្ព ឆ្ព ថ្ព ថ្ព ផ្ត ផ្ឆ

ស្ត ស្ដ ស្ព ម្ក ម្ច ម្ឈ ម្ត ម្យ ម្ហ ម្អ ល្ខ ល្ប ល្ហ ល្អ

២- ពួកព្យញ្ជនៈ សំយោគដែលត្រួតជើងអក្សរ ((អ៊)) ចុងវគ្គ និង សេសវគ្គ

ឧ ៖ ក្ង ខ្ញ ឆ្ន ស្ម ខ្យ ត្រ ថ្វ ស្ល

ជើងអក្សរទាំងនេះ ត្រូវដួលសម្លេងទៅតាមតួអក្សរខាងលើជានិច្ច ។

# មេរៀនពិសេស

្ក ្ខ ្គ ្ឃ ្ឈ ្ង ្យ ្ព ្ប ្ហ ្អ

ខ្ជ ខ្ទ ខ្ព ឆ្គ ឆ្ព ថ្គ ថ្ព ផ្ល ផ្ទ ស្គ ស្ល ស្ព

ម្ន ម្ខ ម្ច ម្ដ ម្ស ម្ហ ម្អ ល្ខ ល្ប ល្ហ ល្អ

ខ្ជឹង ខ្ទម ខ្ពស់ ឆ្គាំឆ្គង ឆ្គុង ថ្គាម ថ្ពាល់

ថ្ពីន ផ្លូវ ផ្ទះ ស្លូវ ស្គាល់ ស្ពាន ស្ពៃ

ម្នាក់ ម្ខាង ម្ចាស់ ម្ដាយ ម្សៅ ម្អម ក្ដាម

ល្ខោន ល្បី ល្បែង ល្ហុង ល្អី ។



# អក្សរផ្ញើជើង

ត្រីខ្ទឹង ដំណើរខ្ចើច ខ្ចមស្អឹក ថ្កាមខ្លា ថ្គីនភ្នែក ផ្តីអាចម៍មាន់ ចេកអំបូងពីរស្លង ស្តែក្តោប ម្តាយចុង ខ្យល់បក់ល្ហើយ ភ្ជួកទឹកល្អក់ ស្រូវដប់ល្អី ។

ម្តាយខ្ញុំស្លប្រេងដូង គាត់យកខ្ទិះទៅដាក់ក្នុងខ្ទះដាំលើជើងក្រាន ។ នាងសុភីបានឆ្លងមុខពីថ្ងៃអាទិត្យ ។ នៅស្ទឹងមានជ័យ មានប៉ុស្តិ៍វិទ្យុផ្សាយសម្លេងមួយ ។





## -ក្អែកមានគំនិតដែរ-

ក្អែកមួយហើរ ស្រែក ខ្វក ! ខ្វក !រកទឹកផឹក មិនបាន ព្រោះបឹងត្រពាំង ស្រះ រីងខះអស់ ។ ហើរទៅ ហើរមក វាឃើញក្អមតូចមួយមានទឹក កន្លះ។វាផឹកទឹកនោះពុំបាន ព្រោះកវាខ្លី វាក៏តាំង ហើរទៅពាំក្រួស មកទម្លាក់ក្នុងក្អមនោះម្ដងមួយៗ ទាល់តែទឹកឡើងដល់ជិតមាត់ក្អម ,ទើបវាផឹកទឹក នោះទៅ ។



# ទន្សាយចង់ស៊ីចេក

ទន្សាយឃើញយាយទូលចេកដើរមក វាធ្វើជាងាប់ស្តូកនៅជិតផ្លូវ ។ យាយឃើញត្រេកអរណាស់ ក៏រើសទន្សាយ ដាក់ក្នុងល្អីចេក ទូលដើរទៅ ។ ទន្សាយស៊ីចេកឆ្អែតរួចលោតចូលព្រៃបាត់ ។

មកដល់ផ្ទះ យាយដាក់ល្អីចុះ ឃើញតែសំបកចេក ។

យី ! អញចាញ់បោកទន្សាយទេតើ ! ។





# សារិកាកែវ

ខ្ញុំមានសារិកាកែវវងមួយ ។ សម្បុរវាខ្មៅស្រិល មានឆ្នូតលឿងអមសងខាង ។ ខ្ញុំចិញ្ចឹមវានៅក្នុងទ្រុងឈើលាបពណ៌ខៀវ។ សារិកាកែវខ្ញុំចេះត្រាប់មាត់មនុស្ស ។ មានមួយថ្ងៃ អាវងបានស្រែកហៅមនុស្សម្នាក់ថា ((ពូ ! ពូ ! អញ្ជើញទៅណា? ចូលលេងសិន)) ។ ពេលនោះខ្ញុំក៏ស្ទុះចេញមកក្រៅរកមើលមនុស្សនោះមិនឃើញ ។ អាវងក៏ស្រែកក្អាកក្អាយថា << ហាស ! ហាស ! >> ។

# ក កា កិ កី

## កូន : ម៉ាក់ ក កា កី

មិនដឹងជាស្អី   ខ្ញុំមិនរៀនទេ   ខ្ញុំចង់តែគួរ
តាមចិត្តខ្ញុំត្រ្ឋរ   មើលគំនូរគេ   ទើបខ្ញុំសប្បាយ ។

## អក្សរខ្មៅ ៗ

បំបែកឲ្យឃ្លាតទៅ   នាំចិត្តខ្ញុំណាយ   សូមម៉ាក់និយាយ
រឿងព្រេងទាំងឡាយ   ណះណាអ្នកម្ដាយ   បានកូនចូលចិត្ត។

## ម្ដាយ : កូន កែ កៃ កៅ

អក្សរខ្មៅៗ   នេះមានគំនិត   បើកូនមើលរួច
វាប្រាប់រឿងពិត   តាមកូនចូលចិត្ត   រឿងព្រេងអស់នោះ។

## គំនូរទាំងឡាយ

អក្សរនិយាយ   ប្រាប់ឥតមានខ្ចោះ   ប្រាប់ថ្មីឃើសត្វ
កូនមើលដឹងអស់   រឿងព្រេងពីរោះ   ស្រេចនៅអក្សរ។





# គ្រួសារមួយនៅលើមែកឈើ

ក្នុងរបងផ្ទះបូណា និង នារី មានដើមឈើមួយដុះប្រប បង្អួច ។ ចាបមួយគូ ហើរមកទំលើដើមឈើនោះ បំរុង នឹងធ្វើសំបុក ។ ពេលនោះ បូណា និង នារី អើតតាម មាត់បង្អួច ឃើញចាបទាំងពីរពាំស្មៅម្ដងមួយទង ម្ដងមួយ ទង មកធ្វើសំបុកគ្មានទំនេរ ។ នារីនិយាយថា: ចាបទាំង ពីរនេះ វាមកនៅទីនេះហើយ ។ យើងនឹងបានមើលវា តើវាធ្វើសំបុកដូចម្ដេច ។

# ចាបពងដាក់សំបុក

មួយអាទិត្យក្រោយមក បូណា និង នារី ឃើញពងចាបបួន នៅក្នុងសំបុក ។ បន្តិចមក វាឃើញចាបពីរ ហើរមកទំលើមែកមួយ ដែលនៅជិតនោះ ។ ចាបមួយលោតចុះទៅក្នុងសំបុក ។ នារីនិយាយថា : <<ចាបនេះប្រហែលជាចាបមេហើយ ព្រោះមួយថ្ងៃហើយ មួយថ្ងៃទៀត មេចាបចេះតែមកក្រាបពងដដែល >> ។





# ចាបយើងញាស់ហើយ

ថ្ងៃក្រោយមកទៀត នៅពេលដែលចាបមេហើរទៅបាត់ បូណាខំសំឡឹងមើលសំបុកយ៉ាងយូរ ។ វាឆ្ងល់ណាស់ ព្រោះឃើញពងទាំងបួនពីថ្ងៃមុន ក្លាយទៅជាក្បាលបួនតូចៗ ។ ពេលនោះ បូណាលាន់មាត់ថា : <<ក្បាលនោះជាក្បាលកូនចាបទេតើ កូនចាបយើងញាស់ហើយ នារី កូនចាបបួនរបស់យើងមានក្បាលតូច ៗ ល្អណាស់ ខ្លួនក្រហមរងាល >> ។

# មេចាបបញ្ចុកចំណីកូន

នៅពេលដែលនារីមកដល់មាត់បង្អួច មេចាបក៏មកដល់សំបុកដែរ ។ បូណា និង នារី អរណាស់ដោយបានឃើញកូនចាបរញ្ជង់នៅក្នុងសំបុក ។ បូណា និង នារី មិនហ៊ាននិយាយអោយឮទេ ចាំលបមើលចាបមេបញ្ចុកចំណីកូនដូចម្ដេចខ្លះ ។ មិនយូរប៉ុន្មាន បូណា និង នារី ឃើញមេវាពាំដង្កូវមួយម្នាក់ចុះមកទំនៅលើមាត់សំបុក ។ រីឯកូនចាបទាំងបួន ដឹងថាមេវាមកដល់ហើយក៏ហាចំពុះយ៉ាងធំ ត្រង់ទៅលើ ចាំទទួលចំណី ។ វានៅមិនទាន់បើកភ្នែកទេ ។ វាឃ្លានណាស់ ។ វាស៊ីមិនចេះឆ្អែតសោះ ។ មេវារវល់ណាស់ដែរ មួយថ្ងៃៗមេវាស្វែងរកសត្វល្អិត មានដង្កូវ និង កណ្ដូបជាដើម ដើម្បីចិញ្ចឹមកូន ។





# កូនចាបចង់ហើរ

ដប់ថ្ងៃកន្លងមក សំបុកចាបក៏ចង្អៀតអស់ ព្រោះកូនចាបទាំងបួនធំឡើង ៗ ។ វាបើកភ្នែកក្រឡង់ មើលនាយមើលអាយ វាជជុះស្លាបទើបនឹងដុះ ។ កូនចាបមួយនោះចង់ហើរតាមមេវា ។ ប៉ុន្តែឃើញជាញញើតបន្តិច វាមិនធ្លាប់ហើរសោះ ។ មួយស្របក់ក្រោយមក កូនចាបនោះក៏ប្រថុយ ហើរចេញពីសំបុក ។ វាខំទទះស្លាបខ្លីរបស់វា ។វាហើរមិនទាន់រួចទេ ព្រោះវានៅតូចនៅឡើយ វាធ្លាក់មកលើស្មៅកណ្ដាលវាល ។

រីឯមេចាប លុះបានឃើញកូនធ្លាក់ដល់ដី ក៏ហៅកូនឲ្យហើរឡើងទៅសំបុកវិញ ប៉ុន្តែកូនចាបហើរឡើងពុំរួច ខំតពេះតតះនៅលើស្មៅនោះ ។



# កូនចាបធ្លាក់ដី

នារីមកពីសាលារៀនវិញ ឃើញកូនចាបមួយធ្លាក់ដី ក៏ម្ចីត្អ យកកូនចាបនោះ កាន់ដោយថ្នម ៗ ទៅអោយបូណា ។ កូនចាបភ័យចេះតែយំ ។ នារីនិយាយលួងថា : <<កុំយំ ខ្ញុំមិនធ្វើអីកូនចាបឯងទេ ចាំបងបូណាដាក់កូនចាបឯង ទៅក្នុងសំបុកវិញ>> ។ បូណាទទួលយកកូនចាបពីនារី ហើយនិយាយថា : << បងអាណិតមេវាណាស់ បងយកកូនចាបនេះ ទៅដាក់ក្នុងសំបុកវិញ អោយវាជួបជុំបងប្អូនវានឹងម៉ែឪវាផង >> ។ ថាហើយ បូណាក៏ឡើងដើមឈើដាក់ចាបនោះទៅក្នុងសំបុកវាវិញ ។



# ចាបលាយើងទៅហើយ

មួយអាទិត្យមកទៀត កូនចាបទាំងបួន នោះក៏ចេះហើរមែនទែន ។ ខ្លួនវាដុះស្លាបជុំជិត ទាំងអស់ ដូចមេវាដែរ ។ ឥឡូវនេះកូនចាបទាំង បួនហើរទៅរកចំណីខ្លួនវា ។ វាលែងនៅក្នុងសំបុក វា ដូចមុនហើយ ។ វាហើរទៅឆ្ងាយ វាមិន ត្រឡប់មកវិញទេ ។ នារីនិយាយថា : << មើល ហ្ន៎ ! កូនចាបលាសំបុកវាហើរទៅឆ្ងាយហើយ មិន ដឹងជាថ្ងៃណាទេ វានឹងវិលមករកដើមឈើនេះវិញ>>។





# រឿងត្រីដណ្តើមពិស



ពស់ថ្លាន់បានខ្ជាក់ពិសវាចោល អោយសត្វទាំងឡាយទៅយក ។ មានពស់វែករនាម វែកស្រែ រហូតដល់ត្រីអណ្តែង ត្រីកញ្ចុះ ជាដើម ទៅដណ្តើមគ្នាយកពិសពីពស់ថ្លាន់ ។ ចំណែកត្រីក្រមម ទៅយកពិសមិនទាន់គេ ដោយខ្លួនជាប់ក្នុងលប ក៏យំ ហ៊ឺ ! ហ៊ឺ ! ហើមមុខមាត់អស់ ។ ត្រីសណ្តាយទៅដែរ ឃើញត្រីក្រមមមុខហើមក៏សើច ហាស ! ហាស ! ទាល់តែរយះមាត់ច្រវាប ។ ត្រីស្លាត ខំទៅនឹងគេដែរប្រជៀតខ្លួននឹងផ្ទាំងថ្ម ទាល់តែសំប៉ែតខ្លួន រហូតដល់សព្វថ្ងៃនេះ ។



# ថាអរគុណ

## ម៉ាក់សុខញុាំបាយ



សុខឃើញពីឆ្ងាយ ដើរមកក្រឡឹង
ដល់ជិតក្ដួមឃូស អោយម៉ាក់រ៉ាដឹង
ម្ដាយយល់ដំណឹង សុខមករកញុំ ។

## ហុចនំមួយភ្លាម

សុខលូកដៃឆ្ពាម ទាញយកមកខាំ
ភ្លេចថាអរគុណ សុខភ្លេចចំណាំ
ពាក្យពីរមិនចាំ ម្ដាយយកនំវិញ ។

## មៀវ មៀវស្រែកថា

ម្ដាយសុខហៅឆ្មា ទាំងមុខម្នោម្នេញ
ហុចនំទៅឆ្មា ជន្លួជន្លេញ
ឆ្មាតបមកវិញ ង៉ាវ ៗ ង៉ាវ ៗ ។



## ឯងឃើញទេឬ ?

ង៉ាវ ៗ ដែលឮ គឺជាភាសា
សត្វថាអរគុណ តាមរបៀបវា
គិតទៅសត្វឆ្មា ចេះថាជាងសុខ ។





# មុនពេលទៅសាលា

នាឡិកាទើបតែវាយម៉ោងប្រាំមួយកន្លះ។ នារីក្រោកពីដំណេក ដោយរួសរាន់។ នាងទៅលុបលាងមុខអាត់ដុសធ្មេញយ៉ាងស្អាត។ នារីយកកន្សែងសស្អាត មកជូតមុខ ជូតត្រចៀក ហើយសិតសក់ ។ ក្រោយពីស្រស់ស្រូបបបរ នារីស្លៀកពាក់យ៉ាងត្រឹមត្រូវ ។ នារីរៀបចំសៀវភៅប្រដាប់ប្រដាដាក់ក្នុងសំពៀត រួចនាងទៅលាឪពុកម្តាយ នាងទៅសាលា ដោយលើកដៃសំពះ ហើយនិយាយថា៖ ប៉ា ! ម៉ាក់ ! កូនទៅសាលា ។





# តាមផ្លូវទៅសាលា



ដល់ម៉ោងប្រាំពីរ សុភីកណ្ដៀតសំពៀតសៀវភៅ ចុះទៅសាលា។ ផ្ទះនាងមិនឆ្ងាយពីសាលាប៉ុន្មានទេ។ រាល់ពេលទៅសាលា សុភីដើរជាមួយសុខា ដែលជាមិត្តរៀនជាមួយគ្នា ។

សុភីនិងសុខា ដើរទៅសាលាដោយរីករាយ ។ ទាំងពីរនាក់ ដើរលើចិញ្ចើមថ្នល់ ពុំមានហក់លោត ប្រឡែងគ្នាលេង តាមផ្លូវឡើយ ។ មុននឹងឆ្លងថ្នល់ សុភី និង សុខា មើល ឆ្វេង ស្ដាំ ។ លុះត្រាតែគ្មានឃើញរទេះឡាន ឬ កង់ ទើបហ៊ានឆ្លងដោយរួសរាន់ ។





# ពេលចេញលេង

ម៉ឹង ! ម៉ឹង ! គឺជាសូរសម្លេងជួងចេញលេង ។ សិស្សទាំងអស់សប្បាយរីករាយ រត់ចេញប្រញាប់ ពីបន្ទប់រៀនរៀងខ្លួន ។ នៅក្នុងធ្លាសាលាដ៏ធំទូលាយ សិស្សទាំងអស់ចែកគ្នាជាក្រុមៗតាមប្រុសតាមស្រី លេងល្បែងផ្សេងៗដែលគេចូលចិត្ត ។ ក្រុមទាំងនោះលេងល្បែងប្លែកៗគ្នា ។ នារី និង កុមារីឯទៀតលេងត្រែះ ។ បូណា សុផានី លេងតប់វង់ ។ សិស្សឯទៀត ៗ លេងលោតម៉ឹក លោតអន្ទាក់ លោតខ្សែ ។ ទាំងអស់គ្នាលេងសើចក្អាកក្អាយសប្បាយរីករាយណាស់ក្នុងពេលចេញលេងម្តង ៗ ។



# ចំណីទន្សាយ

បូណាចាក់ទឹកដោះគោដាក់កូនចាន ហើយហៅទន្សាយមកជិតប្រាប់ថា : <<លោត ! លោត ! អញអោយទឹកដោះគោឯងផឹក >> ។ ទន្សាយលោតចុះលោតឡើង តែវាមិនផឹកទឹកដោះគោទេ ។ បូណាថា : អានេះរើសចំណីណាស់។

នារីយកស្មៅមកហុចអោយ ទន្សាយវាស៊ីស្មៅភ្លាម ។ នាងសួរបូណាថា : <<ទន្សាយស៊ីអ្វី ?>> បូណាឆ្លើយថា : <<វាស៊ីស្មៅ>> នាងសួរទៀតថា : << ចុះអ្នកណាផឹកទឹកដោះគោ ? >> បូណាឆ្លើយថា : << យើងទេតើផឹកទឹកដោះគោ >>



# សំលៀកបំពាក់បូណានិងនារី



នៅផ្ទះ បូណាស្លៀកខោខ្លី ហើយ លែងខ្លួនទទេ ។ ឯនារីស្លៀកសារុងពុម្ព ពាក់អាវរលុង ។ កាលណាទៅសាលារៀន បូណាស្លៀកខោខ្លី ពាក់អាវពណ៌ស ព្រមទាំងស្បែកជើងសង្រែកផង ។ ចំណែកនារីវិញ នាងស្លៀកសំពត់ខៀវត្រឹមជង្គង់ ពាក់អាវទេសឯកដៃខ្លី ហើយ និង ស្បែកជើងផ្ទាត់កៅស៊ូ ។ សំលៀកបំពាក់បូណាមានហោប៉ៅច្រើនជាងសំលៀកបំពាក់នារី ។ នៅរដូវក្តៅ បូណា និង នារី ពាក់មួករំចេក ។ កាលណាភ្លៀង វាពាក់អាវភ្លៀង ឬ បាំងឆត្រ ។





 

# ដាំអ្វី

ពីរបីថ្ងៃរួចមកហើយ សំអុល និង បូណា ជជែកគ្នា តែពី យើងដាំអ្វី ?

សំអុល << យើងដាំផ្កា ដើម្បីបានបេះហិតនិងបានល្អមើលផង។

បូណា- ទេ ! ខ្ញុំមិនដាំផ្កាទេ ខ្ញុំដាំបន្លែវិញ ព្រោះបន្លែក៏មាន ផ្កា ហើយបានផ្លែស្ល និង ធ្វើអន្លក់ញ៉ាំផង ។

សំអុល- បើដូច្នេះ ខ្ញុំដាំផ្កា ឲ្យបូណាឯងដាំបន្លែ នៅផ្ទះឯងចុះ។

ស្អែកឡើងជាថ្ងៃអាទិត្យ ។ សំអុល និង បូណា ចាប់ធ្វើសួននៅផ្ទះរៀងខ្លួន ។ សំអុលដាំផ្កាសិរមាន់ ផ្កាម្លិះ ផ្កាហូល ផ្កាម៉ោងដប់ ។ ផ្កាទាំងនោះ មានពណ៌ផ្សេង ៗ គ្នា ។

ឯបូណា វាដាំស្ពៃ សាលាដ ខាត់ណា ជីរ ខ្ទឹម ស្លឹកគ្រៃ ម្ទេស ប៉េងប៉ោះ ។



# យើងដាំ



តមក ដើមផ្កាក្នុងសួនសំអុលក៏ធំ មានផ្ការីក បង្ហាញពណ៌ប្លែកៗ ល្អមើលណាស់ ។ ផ្កាខ្លះមានក្លិនក្រអូបសាយ ផ្កាខ្លះទៀតមានតែពណ៌ ។

នៅក្នុងសួនបូណា បន្លែដុះលូតលាស់ធំឡើងដែរ ។ ដើមខ្លះមានស្លឹកធំៗ ។ ដើមខ្លះទៀត មានទាំងផ្លែផង មានក្ដឹប ផ្លែខ្ទី ផ្លែស្រគាល ផ្លែទុំ ។

ថ្ងៃមួយ សំអុលកាច់ផ្កាគ្រប់បែបដែលវាដាំ ផ្ញើទៅអោយបូណាជាមិត្ត ។



ក្រោយមក បូណាបេះផ្លែប៉េងប៉ោះ ដែលមានសំបកក្រហមរលោង ដកសាលាដស្ពៃដែលមានស្លឹកស្រស់ ៗ យកទៅអោយសំអុលវិញ ។

កុមារទាំងពីរនេះ សប្បាយចិត្ត មួយយ៉ាង នឹងដំណាំខ្លួន ដុះបានល្អ មួយយ៉ាងទៀត នឹងបានផ្កា និង ផ្លែដំណាំ បង្អួតគ្នា ទៅវិញទៅមក ។



# ស្រមោចធ្វើការ

ពីថ្ងៃអាទិត្យមុន បុណ្ណាកំពុងស្រោចផ្កានៅមុខផ្ទះវា ។ ពេលនោះ ចាន់ថា មកលេងនឹងបុណ្ណា ក៏ចូលទៅក្នុងសួនជាមួយគ្នា ។ ក្រឡេកទៅកៀនគុម្ពផ្កា ចាន់ថាឃើញស្រមោចជាច្រើន ហើយស្រែកហៅបុណ្ណាថា ៖ << បុណ្ណា. មក មើលស្រមោចច្រើនណាស់វ៉ុយ ! >> ។

បុណ្ណា - យី ! សុទ្ធតែស្រមោចភ្លើង កុំទៅជិតវា ប្រយ័ត្នវាខាំ ។ មើលហ្ន៎ ចាន់ថា ! ស្រមោចមួយពួកនេះវាកំពុងធ្វើសំបុក ទុកការពារទឹកភ្លៀងខ្យល់។ មួយពួកនេះទៀត ជញ្ជូនគ្រាប់ស្រូវ អង្ករយកទុកដាក់ សម្រាប់ពេលអត់ឃ្លាន។ ឯក្រុមនេះ ក្បាលមីរដេដាស វាខំប្រឹងពាំទាញ អូសមេអំបៅមួយយកទៅដាក់ ក្នុងសំបុក ដែលពួកវាខ្លះទៀតកំពុងធ្វើការ ។

បុណ្ណា និង ចាន់ថា មានចិត្តរីករាយ ហើយកោតសសើរស្រមោចដែលមាន គំនិតចេះជួយគ្នាធ្វើការឥតឈប់ឈរ ។





# ទៅលេងផ្ទះអ៊ំកេត

ថ្ងៃនេះជាថ្ងៃអាទិត្យ ។ ម្ដាយបូណា បាននាំបូណាទៅលេងផ្ទះអ៊ំកេត ។

– ម៉ែចបូណា រៀបចំខ្លួនរួចហើយ ?

– បាទ ! រួចស្រេចហើយម៉ាក់ អញ្ជើញ ។

បន្តិចក្រោយមក ម្ដាយបូណា និង បូណា បានទៅដល់ផ្ទះអ៊ំកេត ។ ទៅដល់ទ្វាររបង បូណារត់ចូលទៅមុនម្ដាយវា ហើយស្រែកដោយរីករាយ ដោយលើកដៃសំពះ យ៉ាងសមរម្យ ។



– ជំរាបសួរអ៊ំ ។

– អើ បូណា ! អ្នកណាមកខ្លះ ?

– បាទ ម៉ាក់អញ្ជើញមកដែរ នៅខាងក្រៅ ។ បូណាសប្បាយចិត្តណាស់កាលណាបានមកលេង ផ្ទះអ៊ំកេតម្ដង ៗ ។

 

# ម្ដេចក៏ក្អែកមិនស្រឡាញ់ទីទុយ

កាលនោះ ក្អែកនិងទីទុយមានគំនិតផ្ដើមឡើងថា ៖ គួរតែសត្វស្លាបទាំងឡាយមានពណ៌សម្បុរប្លែក ៗ គ្នា ។

ក្អែក ៖ ខ្ញុំអាចដាក់ពណ៌ជូនបងទីទុយឯងអោយបានល្អ ។

ទីទុយ ៖ ខ្ញុំអរណាស់បង រួចខ្ញុំនឹងលាបពណ៌ជូនបងឯងវិញអោយបានពេញចិត្ត ក្អែកដាក់ពណ៌អោយទីទុយដូចសម្បុរវាសព្វថ្ងៃនេះ។លុះឆ្លុះកញ្ចក់មើលទៅទីទុយសប្បាយណាស់ ។ ទីទុយយកធ្យូងបាតឆ្នាំងសម្លមកជូតលើស្លាបក្អែក ហើយថាៈ<ខ្ញុំលាបឲ្យបងក្អែកឯងបានរហ័សណាស់ ខ្ញុំលាហើយ!>។

ក្អែកឆ្លុះកញ្ចក់ទៅ ឃើញស្លាបខ្មៅ ទាស់ចិត្តខ្លាំង ក៏ខឹង ដេញទីទុយ ហើយស្អប់ទីទុយមកដល់សព្វថ្ងៃ ។ ឯទីទុយដឹងខ្លួនថា បានជាជ្រុលកំប្លែងឥតទំនងក៏លែងហ៊ានចេញរកស៊ីពេលថ្ងៃ ។

 

# - នៅច្បារ -



រាល់ល្ងាចម៉ោងប្រាំ   តាមខ្ញុំចំណាំ
ប៉ាចូលក្នុងច្បារ   ស្រោចទឹកដកស្មៅ
ដង្កូវនានា   បេះចេញពីផ្កា
    មិនអោយសល់មួយ ។
ត្រសក់និងល្ពៅ   ម្ទេសត្រប់ឥឡូវ
កំពុងបែកត្រួយ   ត្រឡាចឡើងទ្រើង
ចេញផ្កាមួយៗ   ទងងើបបោះពួយ
    ដណ្តើមទីត្ថា
ប៉ាជ្រុំជ្រួយដី   ខ្ញុំទាញបានល្បើ
រូតរះម្ទីម្ទា   រត់រកកើបដី
អាចម៍មាន់អាចម៍ទា   អាចម៍គោផងគ្នា
    អោយចំណីច្បារ ។
ប៉ាសើចដាក់ខ្ញុំ   ថាដល់បាធំ
បាចេះធ្វើការ   ចេះដាំដំណាំ
បានស្លឹកផ្លែផ្កា   ចិញ្ចឹមគ្រួសារ
    មិនព្រួយទិញគេ ។





# ភ្លៀងនៅពេលទៅសាលា

ថ្ងៃនេះ មេឃស្រទំតាំងពីព្រឹកម្ល៉េះ ។

បូណា និង នារី រៀបចំខ្លួនទៅសាលា ។

បូណាចេញមកហោជាំង សំឡឹងមើលមេឃ ហើយ និយាយថា : <<ល្ងាចនេះច្បាស់ជាភ្លៀងធំហើយ បងត្រូវយកឆត្រទៅផង ក្រែងលោភ្លៀង នៅតាមផ្លូវទៅសាលា>> ។ ដោយបូណាត្រូវទទួលមិត្តថ្មីមួយផង បូណាក៏សូមលាម្ដាយទៅមុននារី ។ បូណាទើបតែទៅផុត ស្រាប់តែឮសូរប្រែះ ៗ ឯលើដំបូលផ្ទះ ។ នារីរត់ចេញមកក្រៅ ហើយ



ស្រែកថា : <<អុញ ភ្លៀងស្រេច បងបូណាថាត្រូវមែន >> ។ ភ្លៀងធ្លាក់កាន់តែខ្លាំងឡើង ៗ នារីទីទើរមិនចង់ទៅរៀន ។



# នារីបាំងឆត្រធំ

មួយស្របក់ក្រោយមក នារីនឹកឃើញឆត្ររបស់ឪពុកនាង ហើយចូលក្នុងបន្ទប់យកឆត្រនោះ មកអោយម្តាយបើកអោយ ។ ម្តាយឃើញកូនកាន់ឆត្រ ក៏ញញឹមហើយនិយាយថា : <<កូនឯងតូចណាស់ បាំងឆត្រនេះមិនសមទេ>> នារីឆ្លើយ : << ថ្ងៃនេះ ខ្ញុំបាំងឆត្រធំ កុំអោយទទឹកភ្លៀង ព្រោះភ្លៀងធំដែរ >> ។ ម្តាយបើកឆត្រហុចទៅអោយកូន ។ នារីបានឆត្រហើយ លាម្តាយទៅសាលា ។ បើអ្នកណាបានឃើញនារីពីចម្ងាយ គេឃើញវា ដូចជាសត្វចម្លែកមួយក្បាលទើងមើងមូលខ្មៅ មានជើងតូច ៗ ដូចជើងមនុស្សដើរទើមៗ។ ភ្លៀងជិតរាំងទៅវិញហើយ ទឹកហូរគគុកតាមស្នាមភ្លោះសងខាងផ្លូវ ។ នារីដើរកាត់ភក់ដោយពិបាក ស្បែកជើងកៅស៊ូ ចេះតែស្អិតជាប់ភក់ ហើយផ្ចាត់ភក់ប្រឡាក់ខ្នងអាវនាង ។ នារីទ្រាំពុំបាន ក៏ដោះស្បែកជើងពាក់នឹងតំពក់ឆត្រ ដើរជើងទទេទៅវិញ ។

# នារីរើសបានស្វាយទុំ

ភ្លៀងមិនទាន់ដាច់គ្រាប់ទេ ខ្យល់បក់ម្តង ៗ ត្រូវឆត្រនារី ។ ឆត្រទាញនារីម្តងទៅឆ្វេង ម្តងទៅស្តាំ ជួនកាលទាញចូលភក់ ។ ភក់ខ្ទាតប៉ប្រិកប៉ប្រាក់ប្រឡាក់ជើងនារីដល់ក្បាលជង្គង់ ។ នារីនៅតែសប្បាយជាធម្មតា ។ នារីដើរចៀសភក់ឡើងលើស្មៅចិញ្ចើមថ្នល់ ។ ពេលនោះស្វាយទុំមួយធ្លាក់ខ្ទុកនៅខាងមុខនាង ។ នារីត្រេកអរណាស់ ស្ទុះទៅរើសភ្លាម ហើយនិយាយម្នាក់ឯងថា : អែយ៉ា ! ស្វាយក្បាលដំរីនេះទុំក្រហមរលោង ។ នារីចង់ញ៉ាំផ្លែស្វាយនេះណាស់ ប៉ុន្តែនាងនឹកឃើញដល់បណ្តាំម្តាយនាងថា កុំអោយញ៉ាំចំណីនៅតាមផ្លូវ ព្រោះវាមិនស្អាតដូចនៅផ្ទះទេ ។ នារីដកយកកូនកន្សែងចេញពីសំពៀតហើយវេចស្វាយទុំ ព្យួរទៅនឹងតំពក់ឆត្រ រួចចុះទៅលាងជើង នៅស្នាមភ្លោះ ។ ដល់ឡើងមកវិញ នាងយកស្បែកជើងពាក់ ដើរតម្រង់ទៅសាលា ។





# នារីទៅដល់សាលា

ភ្លៀងរាំងមួយស្របក់ហើយ ។ ស្លឹកឈើទាំងឡាយឡើងស្រស់ញញឹម ផ្ទល់ក៏ស្អាត ។ ក្នុងស្នាមភ្លោះ ទឹកនៅហូរនៅឡើយ ។ នារីនៅតែបាំងឆត្រធំធ្វើព្រងើយ ។នាងដើរដល់បន្ទប់រៀន ។

អ្នកគ្រូឃើញឆត្រធំខ្មៅចម្លែកមកជិត ក៏ស្រែកសួរថា : <<អ្នកណាហ្នឹង ?>> នារីឆ្លើយភ្លាម : <<ចាស ! ខ្ញុំណាអ្នកគ្រូ>> អ្នកគ្រូលើកឆត្របើកមើល ឃើញនារីសើចគ្រហាញ។ អ្នកគ្រូញញឹមតបវិញ រួចយកកូនកន្សែង មកជូតមុខ ជូតខ្លួនឲ្យនារីហាក់ដូចជាកូនសម្លាញ់។ ឃើញ ថា ស្អាតហើយ ទើបបាន អោយនារីទៅលេងជាមួយនឹង សិស្ស ៦ ទៀត ៗ ។





# ពេលបាយ

ម្ដាយ - ឯណាសំអុល ទៅណាហើយ ?

សំអុល - អត់ទោសម៉ាក់ ខ្ញុំកំពុងលាងដៃ ។ សំអុលរត់មកដោយញាប់ប្រញាល់ ។ សំអុល - ម៉ាក់ កូនញ៉ាំភ្លានេះបានឬទេ ? ម្ដាយ - ទេ ភ្លានេះសំរាប់ម៉ាក់និងបងឯងទេ ។ សំអុលឯងញ៉ាំតែសាច់អាំង និង សម្លនេះបានហើយ ។ ក្មេងៗពោះខ្ចីញ៉ាំភ្លាមិនបានទេ ។ សំអុល - ម៉ាក់ ឲ្យកូនសុំកន្សែងនោះគ្រប់ខោដូចបងផង ។ ម្ដាយ - អើ យកចុះធ្វើដូចនេះទើបត្រូវ ។ សំអុល - ម៉ាក់ ខ្ញុំសុំឈើចាក់ធ្មេញមួយ ។ ម្ដាយទេ ! កូនកុំចាក់ខ្លាចខូចធ្មេញ ញ៉ាំរួចកូនយកច្រាសដុសធ្មេញតែម្ដងទៅ ។



# ផ្លាចិញ្ចឹមសត្វ

ថ្ងៃព្រហស្បតិ៍ សុខាមិនទៅសាលាទេ ។ វាចូលចិត្តនៅលេងជាមួយនឹងសត្វឯផ្លា ។ មើលចុះ គួរអោយសប្បាយមែន នៅផ្លាចិញ្ចឹមសត្វឯនេះ មានមេមាន់បណ្ដើរកូន ក្រុកចុះក្រុកឡើង ហៅកូនចែកចំណី នៅជិតនោះ មាន់បាមួយងើបក្បាល ទទះស្លាប រងាវ ។

ឯនោះ ក្ងានមួយហ្វូងខំដក ក ស្រែកងោៗ ។ ខាងលើដំបូលព្រាបកំពុងហើរក្រឡឹងផ្ទះវា ។ នៅត្រពាំង ទាខ្លះហួរភក់ ទាខ្លះហែលទឹក ប្រដេញគ្នា ។ ក្នុងទ្រុង ទន្សាយក្រាបស៊ីស្មៅញាប់មាត់ស្មេ ។ ឯជ្រូកបក់កន្ទុយរវិចៗ ឈ្ងោកឈ្ងុសដីស្រែកអ៊ឹកៗ ។ មិនឆ្ងាយពីនោះប៉ុន្មានកូនគោឈរជ្រែងជើងងើបក្បាលបៀដោះមេវា ។ សត្វទាំងអស់នេះ ជាមិត្តនឹងសុខា ។ សុខាតែងអោយចំណីនិងអង្អែលវាលេងជារាល់ថ្ងៃ ។







# ចាបស្រុក

ម៉ោងប្រាំមួយហើយ ខាងក្រៅផ្ទះ សូរមាន់សត្វយំទ្រហឹង ។ ម្ដាយសានបើកបង្អួចឡើង ឃើញចាបស្រុកជាច្រើននៅលើមែកម្រៀន ។ គាត់ចូលទៅដាស់សាន

-កូន ! ក្រោកឡើង ភ្លឺហើយ ។

-ខ្ញុំនៅងងុយគេងណាស់ ខ្ញុំមិនទាន់ក្រោកទេ ។

-កូននៅងងុយ ព្រោះកូនចូលដំណេកខុសពេល ។ ឃើញទេ ចាបភ្ញាក់ទៀងពេលណាស់ ព្រោះវាចូលដំណេកក៏ត្រូវពេលដែរ ។

ចូរកូនមើលតាមបង្អួចនេះ ចាបកំពុងជជែកគ្នា ។ វាជជែកគ្នាអំពីមេរៀន អំពីការរកស៊ី អំពីការ ដែលវាត្រូវធ្វើក្នុងថ្ងៃនេះ ។

សានឮដូច្នេះ ក៏ក្រោកទៅមើលចាបតាមបង្អួច ។ វាបានស្វាងស្រឡះមុខ បាត់ងងុយ ។

សាននិយាយប្រាប់ម្ដាយវាថា : <<ស្អែកខ្ញុំនឹងក្រោកអោយបានស្មើនឹងពួកចាបទាំងនេះ មិនចាំអោយម៉ែដាស់ខ្ញុំទេ >> ។

# បុណ្ណាថាត្រូវមែន



តាំងពីព្រលឹម មេឃមិនទាន់ស្រឡះសោះ មានពពករសាត់ទាំងផ្ទាំងៗ ។ ខ្យល់ត្រជាក់ ប្លែក បក់មករំភើយ ៗ ។

សំអុល - ខ្យល់ត្រជាក់អីម្លេះព្រឹកនេះ ។

បុណ្ណា - កាលណាមានខ្យល់ត្រជាក់បែបនេះ យើងចំណាំបានទេ ថាភ្លៀងជិតធ្លាក់ហើយ។

សំអុល - ទេ ដូចជាមិនមែនទេ ។

បុណ្ណា - យើងសង្កេតត្រូវជាច្រើនដងហើយ យើងបានទាំងចំណាំទៀតថា បើពេលយប់មានផ្លេកបន្ទោរ ច្រើនមានភ្លៀងដែរ ។

នៅពេលចេញទៅសាលា បុណ្ណាមិនយកសំពៀតទេ ។ ថ្ងៃនេះវាដាក់សៀវភៅ ក្នុងថង់កៅស៊ូហើយយកអាវភ្លៀងទៅផង ។ ឯសំអុលមិនធ្លាប់មានការសង្កេត មិនជឿបុណ្ណា ក៏ចេញទៅ ឥតប្រុងប្រៀប ។ ដល់ពាក់កណ្ដាលផ្លូវ ស្រាប់តែភ្លៀងធ្លាក់ឈូ ។ សំអុលមិនបានយកឆត្រអាវភ្លៀងមក ក៏រត់ទៅកាត់ស្លឹកចេក មួយកំណាត់ធាង យកមកទទូរ។ វាចៀសវាងទទឹកខោអាវមិនរួចទេ តែវាអាចការពារសៀវភៅវាអោយនៅស្ងួតបាន ។



សំអុល - បើជឿបុណ្ណាមិនអីសោះ ។

បុណ្ណាថា ត្រូវមែន ! ។



# ទន្សាយ និង ខ្យង

ខ្យងឮថាទន្សាយល្បីខាងខិលខូច ហើយមានប្រាជ្ញាណាស់ ។ វាចង់ផ្ចាញ់ទន្សាយល្បងមើល ។ថ្ងៃមួយ ទន្សាយកំពុងតែផឹកទឹក ឮខ្យងស្រែកថា ៖ << បងទន្សាយផឹកទឹកនេះ សុំអ្នកណា ? >>

ទន្សាយខឹងណាស់ ក៏ឆ្លើយទៅវិញថាៈ<<បើអញផឹកទឹកនេះទើសក្បាលអីឯង ! អាវារគើម ៗ មួយថ្ងៃដើរមិនបានមួយចំអាមផងនោះ ! >> ។

ខ្យងតបវិញថា : << អញដើរគើម ៗ មែន តែបើឯងចង់រត់ប្រណាំងនឹងអញលមើល ជុំវិញត្រពាំងនេះ អញក៏មិនខ្លាចឯងដែរ >> ។

ទន្សាយ - រត់ប្រណាំងនឹងអញ ! រត់ក៏រត់ ! ចុះបើអញរត់ឈ្នះ ឯងធ្វើម្ដេច ?

ខ្យង - បើឯងរត់ឈ្នះអញ អញនឹងលែងនៅក្នុងត្រពាំងនេះ។ ចុះឯងវិញ ?

ទន្សាយ - បើអញរត់ចាញ់ឯង អញនឹងលែងផឹកទឹកត្រពាំងបឹង បួររហូត ។



លុះព្រឹកឡើង សត្វទាំងពីរក៏រត់ប្រណាំងគ្នា ។ រត់មួយស្របក់ ទន្សាយស្រែកហៅខ្យង : << អីបងខ្យង >>

ខ្យងនៅខាងមុខឆ្លើយ : << គូក ! >>

ទន្សាយធ្វើស្លឹកត្រចៀកមីងមាំង រួចវាបោលរឹងទៅទៀត ។ រត់មួយស្របក់ ក៏តាំងហៅខ្យងម្តងទៀត : << អីបងខ្យង >>

ខ្យងនៅឯមុខឆ្លើយយ៉ាងខ្លាំង : << គូក ! >>

ឮភ្លាមទន្សាយលោតជើងពីរ ជើងបី បោលហុយដីទ្រលោម វាខំប្រឹងរត់យ៉ាងលឿន លើសមុនទៅទៀត ។ លុះរត់បានមួយស្របក់ទៅ ទន្សាយក៏ស្រែកហៅខ្យងម្តងទៀត :

<< អីបងខ្យង >>

ខ្យង : << គូក ! >>

ទន្សាយភ្ញាក់ខ្លួនព្រើត លោតច្រឡោតតោតតួង រត់ទាល់តែទន់លោង ដួលនៅនឹងកន្លែង សុខចិត្តចាញ់ខ្យង ។ ដោយហេតុនេះហើយ បានជាទន្សាយលែងផឹកទឹកត្រពាំង បឹង បួ ផឹកតែទឹកសន្សើមរហូតដល់សព្វថ្ងៃនេះ ។





# គីង្គក់ និង មាន់ចែ

មាន់ - ហេតុអីបានជាបងគីង្គក់ឯងស្រែក ក្រត ក្រត យ៉ាងនេះ ?

គីង្គក់ - បាទបង ! ខ្ញុំស្រែកដើម្បីអោយដំណឹងដល់គេឯងថាភ្លៀងជិតធ្លាក់ហើយ ។

មាន់ - ឃឺ ! មុននឹងភ្លៀង បងឯងដឹង ? ចុះបងឯងចំណាំបែបណា ?

គីង្គក់ - ខ្ញុំថាមិនខុសទេ ព្រោះការចំណាំរបស់ខ្ញុំប្រាកដណាស់ ។

នៅមុនពេលភ្លៀង ខ្ញុំតេះតែធ្ងន់ក្បាល ។ ចុះបងឯងចំណាំបែបណាដែរ បានជារងាយទៀងពេលម្លេះ ? តែជិតភ្លឺឡើងឮសូរតែមាត់ផ្អើលគេ ផ្អើលឯងគ្រប់គ្នា ។

មាន់ - ខ្ញុំដឹងពេលជាក់ណាស់ គឺថាជិតភ្លឺ គូទខ្ញុំវារហើយ រួចតែរហើយ ខ្ញុំរងាយមួយស្រពក់ទៅ ភ្លឺហើយ ។

គីង្គក់ចង់បំភាន់មាន់ ក៏ទៅលេបផ្លុំគូទមាន់ពីក្រោម ។ មាន់រហើយគូទជុះ ប្រិចរួចទើបរងាយ ។ អាចម៍មាន់ធ្លាក់ខ្ទុកមកចំកណ្តាលក្បាលគីង្គក់ ។ ឯគីង្គក់ធ្ងន់ក្បាលខំស្រែកអស់ទំហឹង កោកកាក អ៊ូអរតែមិនភ្លឺមិនភ្លៀងសោះ ។



# ខ្ញុំស្រឡាញ់អ្នកណាខ្លះ !



## ខ្ញុំស្រឡាញ់ម៉ាក់

ចូលចិត្តផ្អមថ្នាក់　ចិញ្ចឹមរក្សា
ខ្ញុំនិងបងប្អូន　គ្រប់ពេលវេលា
ខុសម្តងម្កាគ្រា　ម៉ាក់ឆាប់អត់អោន ។

## ខ្ញុំស្រឡាញ់ប៉ា



រាល់ថ្ងៃធ្វើការ　មកចិញ្ចឹមកូន
ចិញ្ចឹមគ្រួសារ　ជីតាជីដូន
នឿយហត់បាត់សូន្យ　បើឃើញខ្ញុំរៀន។

## តាយាយខាងប៉ា

ខាងម៉ាក់ផងណា　ចិត្តខ្ញុំក៏មាន
ស្រឡាញ់ដូចគ្នា　ព្រោះចេះនិទាន
រឿងព្រេងកំសាន្ត　ប្រដៅអោយជា។

## ខ្ញុំស្រឡាញ់ប្អូន



តូចធំក៏កូន　ម៉ាក់ប៉ាដូចគ្នា
ខ្ញុំមើលសៀវភៅ　អូនដើរមកសៀរ
កេះខ្ញុំហើយវា　គ្រាប់តាមមាត់ខ្ញុំ។